**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:២៥២ អនក្រ.បក**

**អនុក្រឹត្យ**

**ស្ដីពី**

**ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៧១០០ ហិកតា ស្ថិតក្នុងឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្ដូងថ្ម សំរុង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់ និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនិតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៤២សជណ.ថក ចុះថ្ងៃទី២៧ ខែតុលាឆ្នាំ២០០៩ ស្តីពី គោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.~**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ទីតាំងដី ១ កន្លែងមានទំហំ ៧១០០ (ប្រាំពីរពាន់មួយរយ) ហិកតា នៅក្នុងឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរុង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM Zone 48 N, Datum: WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|---|---|---|
| A | 355512 | 1173301 | J | 358369 | 1185173 | S | 359229 | 1172157 |
| B | 355512 | 1177920 | K | 362429 | 1182684 | T | 357803 | 1172296 |
| C | 356289 | 1178287 | L | 364268 | 1182780 | U | 355623 | 1173228 |
| D | 356308 | 1182292 | M | 364277 | 1178878 | V | 357348 | 1172819 |
| E | 357449 | 1183019 | N | 361529 | 1176936 | W | 357403 | 1172651 |
| F | 356644 | 1184162 | O | 362509 | 1173639 | X | 357175 | 1172651 |
| G | 357040 | 1184581 | P | 360314 | 1172246 | Y | 357106 | 1172506 |
| H | 357286 | 1184460 | Q | 360250 | 1172939 | Z | 357145 | 1172256 |
| I | 357599 | 1185006 | R | 359381 | 1172772 | | | |



www.pheakdeylaw.com

**មាត្រា ២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំចំនួន ៧១០០ (ប្រាំពីរពាន់មួយរយ) ហិកតា ដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះដែលជាដីក្នុងផែនទីគម្របព្រៃឈើឆ្នាំ ២០០២ មកជាដីឯកជនរបស់រដ្ឋ ។

**មាត្រា ៣.-**

ត្រូវបានប្រគល់អណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ២ ខាងលើនេះ ជូនអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ និងសម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សមាជិក គសសដ
- អគ្គលេខាធិការដ្ឋាន គសសដ
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com

## ចំនុចនិយាមការនៃប្រពន្ធ័កូអរដោនេ 48 N_ UTM, WGS 84 របស់ទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៧.១០០ (ប្រាំពីរពាន់មួយរយ) ហិកតា

## ស្ថិតនៅ ឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរុង នៃស្រុកព្រៃនប់ និង ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

ឧបសម្ពន្ធ័អនុក្រឹត្យលេខៈ ២៥២.អនក្រ.បក...ចុះថ្ងៃទី...០៧......... ខែ វិច្ឆិកា..... ឆ្នាំ ២០១១

| ចំណុច | X | Y |
|---|---|---|
| A | 355512 | 1173301 |
| B | 355512 | 1177920 |
| C | 356289 | 1178287 |
| D | 356308 | 1182292 |
| E | 357449 | 1183019 |
| F | 356644 | 1184162 |
| G | 357040 | 1184581 |
| H | 357286 | 1184460 |
| I | 357599 | 1185006 |
| J | 358369 | 1185173 |
| K | 362429 | 1182684 |
| L | 364268 | 1182780 |
| M | 364277 | 1178878 |
| N | 361529 | 1176936 |
| O | 362509 | 1173639 |
| P | 360314 | 1172246 |
| Q | 360250 | 1172939 |
| R | 359381 | 1172772 |
| S | 359229 | 1172157 |
| T | 357803 | 1172296 |
| U | 355623 | 1173228 |
| V | 357348 | 1172819 |
| W | 357403 | 1172651 |
| X | 357175 | 1172593 |
| Y | 357106 | 1172506 |
| Z | 357145 | 1172256 |

www.pheakdeylaw.com

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៧.១០០ (ប្រាំពីរពាន់មួយរយ) ហិកតា
ស្ថិតនៅ ឃុំពាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរុង នៃស្រុកព្រៃនប់ និង
ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
ឧបសម្ពន្ធ័អនុក្រឹត្យលេខ: ២៥២.អនក្រ.បក ចុះថ្ងៃទី ...០៣... ខែ វិច្ឆិកា ... ឆ្នាំ ២០១១




www.pheakdeylaw.com